## គំរោងចាក់ថ្នាំបង្ការរោគ  រដ្ឋញូវសៅវែល

បើកមើលវ៉ិបសាយរបស់ក្រសួងសុខាភិបាលរដ្ឋញូវសៅវែល ដើម្បីមើលគំរោងចាក់ថ្នាំបង្ការរោគ  NSW បច្ចុប្បន្ននៅត្រង់: www.health.nsw.gov.au/immunisation/schedule

## Save the Date to Vaccinate (កត់ទុកកាលបរិច្ឆេទដើម្បីចាក់ថ្នាំបង្ការរោគ)

ជាការសំខាន់ដែលត្រូវឲ្យប្រាកដច្បាស់ថា  ការចាក់ថ្នាំបង្ការរោគត្រូវធ្វើ**ទាន់ពេល**  ដើម្បីឲ្យទារកបានទទួលការការពារទាន់ពេល  និងកុំឲ្យមានគ្រោះថ្នាក់ឆ្លងរោគធ្ងន់ធ្ងរ។  ប្រូក្រាមទូរស័ព្ទ App 'Save the Date to Vaccinate' អាចជួយអ្នកឲ្យប្រាកដច្បាស់ថាការចាក់ថ្នាំបង្ការរោគរបស់កូនអ្នកបានធ្វើទាន់ពេល។




សូមឆែកមើលវ៉ិបសាយ 'Save the Date to Vaccinate' ដើម្បីទទួលព័ត៌មាន  និងធនធានមានប្រយោជន៍ទាំងឡាយដូចជា សមត្ថភាពដើម្បីបោះពុម្ពគំរោងចាក់ថ្នាំបង្ការរោគដែលធ្វើតាមរបៀបផ្ទាល់ខ្លួន  សម្រាប់កូនរបស់អ្នក និងខែ្សវីឌីអូនៅត្រង់:  www.immunisation.health.nsw.gov.au




## កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ (សៀវភៅពណ៌ខៀវ)

ជាការសំខាន់ដែលត្រូវយកមកជាមួយនូវសៀវភៅពណ៌ខៀវរបស់កូនអ្នកសម្រាប់ការណាត់ជួបនីមួយៗ  ដើម្បីឲ្យវេជ្ជបណ្ឌិត/គិលានុបដ្ឋាកកត់ត្រាការចាក់ថ្នាំបង្ការរោគរបស់កូនអ្នក។

## ហ៊្វមកំណត់ត្រានៃការចាក់ថ្នាំបង្ការរោគសម្រាប់មនុស្សពេញវ័យ

*ហ៊្វមកំណត់ត្រានៃការចាត់ចែងថ្នាំបង្ការរោគសម្រាប់មនុស្សពេញវ័យ* អាចទទួលយកបាននៅតាមវ៉ិបសាយ www.health.nsw.gov.au/immunisation ដែលអាចជួយអ្នកកត់ត្រាការចាក់ថ្នាំបង្ការរោគរបស់អ្នក។

## ព័ត៌មានបន្ថែម

### វ៉ិបសាយក្រសួងសុខាភិបាល  រដ្ឋញូវសៅវែល
www.health.nsw.gov.au/immunisation

### វ៉ិបសាយបញ្ជីចាក់ថ្នាំបង្ការរោគកុមារភាពអូស្ត្រាលី
www.humanservices.gov.au/customer/services/medicare/australian-childhood-immunisation-register

### វ៉ិបសាយកម្មវិធីចាក់ថ្នាំបង្ការរោគអូស្ត្រាលីរបស់ក្រសួងសុខាភិបាល  រដ្ឋាភិបាលអូស្ត្រាលី
www.immunise.health.gov.au

### កម្មវិធីចាក់ថ្នាំបង្ការរោគក្អកមាន់មុនពេលសម្រាលកូន រដ្ឋញូវសៅវែល
www.health.nsw.gov.au/protectnewborns

SHPN  (CHP) 130428
March 2015 © NSW Ministry of Health.

Khmer

# ការមានផ្ទៃពោះ

## ការការពារ  និងការចាក់ថ្នាំបង្ការរោគ ចាប់ពីមុនកំណើត ទៅពេលសម្រាលកូន



NSW GOVERNMENT | Health

# មុនពេលអ្នកមានផ្ទៃពោះ

មុនពេលមានផ្ទៃពោះ គឺជាការសំខាន់ដែលអ្នកត្រូវចាក់ថ្នាំបង្ការរោគរបស់អ្នកឲ្យបានទាន់បច្ចុប្បន្នភាព ដោយហេតុថាភាពស៊ាំនឹងជម្ងឺរបស់អ្នកនឹងត្រូវចម្លងទៅឲ្យទារករបស់អ្នក ហើយការនេះនឹងផ្តល់នូវការការពារក្នុងប៉ុន្មានសប្តាហ៍ដំបូងនៃជីវិតរបស់ទារក មុននឹងគេអាចទទួលការចាក់ថ្នាំបង្ការរោគ។ រោគឆ្លងមួយចំនួនអាចធ្វើឲ្យអន្តរាយដល់ការមានផ្ទៃពោះរបស់អ្នក ដូច្នេះគឺជាការប្រសើរបំផុតដែលអ្នកត្រូវទទួលការការពារមុនពេលអ្នកមានផ្ទៃពោះ។ ការធ្វើតេស្តឈាមដ៏សាមញ្ញមួយអាចបង្ហាញថាតើអ្នកបានទទួលការការពារឬអត់។

## រោគកញ្ជ្រឹល ស្រឡទែន និងស្អូច (MMR)

ប្រសិនបើអ្នកឆ្លងរោគកញ្ជ្រឹល ស្រឡទែន ឬស្អូចក្នុងអំឡុងពេលមានផ្ទៃពោះ អ្នកអាចរលូតកូន សម្រាលកូនមិនគ្រប់ខែ ឬទារករបស់អ្នកអាចកើតមកមានភាពពុំគ្រប់លក្ខណៈពីកំណើតដ៏ធ្ងន់ធ្ងរ។ ប្រសិនបើអ្នកពុំបានទទួលការការពារទេ អ្នកគួរតែចាក់ថ្នាំបង្ការរោគ។ ជាការសំខាន់ដែលអ្នក**ពុំត្រូវមានផ្ទៃពោះក្នុងរយៈពេល២៨ថ្ងៃ បន្ទាប់ពីបានចាក់ថ្នាំបង្ការរោគ។**



## រោគអុតតូច(អុតស្វាយ)

រោគអុតស្វាយអាចបណ្តាលឲ្យមានភាពពុំគ្រប់លក្ខណៈពីកំណើតយ៉ាងធ្ងន់ធ្ងរ ប្រសិនបើអ្នកឆ្លងរោគនេះក្នុងអំឡុងពេលមានផ្ទៃពោះ។ អ្នកគួរចាក់ថ្នាំបង្ការរោគ ប្រសិនបើអ្នកពុំបានទទួលការការពារទេ។ **បន្ទាប់ពីការចាក់ថ្នាំបង្ការរោគ អ្នកត្រូវជៀសវាងកុំឲ្យមានផ្ទៃពោះក្នុងរយៈពេល២៨ថ្ងៃ។**

# ខណៈដែលអ្នកកំពុងមានផ្ទៃពោះ

## រោគរលាកថ្លើមប្រភេទ B

ស្ត្រីមានផ្ទៃពោះគ្រប់រូបត្រូវបានធ្វើតេស្តរកមើលការឆ្លងរោគរលាកថ្លើមប្រភេទ B ដោយហេតុថាវាអាចឆ្លងបន្តទៅទារករបស់គេ ក្នុងអំឡុងពេលសម្រាលកូន។ ប្រសិនបើអ្នកមានជម្ងឺ អ្នកគួរឲ្យគ្រូពេទ្យឯកទេសពិនិត្យមើលអ្នក ហើយទារករបស់អ្នកនឹងត្រូវការព្យាបាលជាមួយថ្នាំពេទ្យមួយហៅថា "អ៊ីមុយណូក្លូប៊ុយលីន" 'immunoglobulin' ហើយទទួលការចាក់ថ្នាំបង្ការរោគរលាកថ្លើមប្រភេទ B ជាបន្ទាន់ ក្រោយពេលសម្រាលកូន។ ដោយគ្មានការព្យាបាលនេះទេ ទារករបស់អ្នកអាចកើតរោគរលាកថ្លើមប្រភេទ B ដ៏រ៉ាំរ៉ៃ ដែលអាចនាំឲ្យមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរទាំងឡាយដូចជាការខូចថ្លើម ឬជម្ងឺមហារីកថ្លើម។

## រោគក្អកមាន់

ពេលប្រសើរបំផុតដើម្បីចាក់ថ្នាំទប់ទល់នឹងរោគក្អកមាន់ គឺនៅក្នុងអំឡុងពេលបីខែចុងក្រោយនៃការមានផ្ទៃពោះ(ជាការល្អគឺនៅពេល២៨អាទិត្យ) នៃការមានផ្ទៃពោះម្តងៗ។ ការនេះនឹងផ្តល់នូវការការពារទាន់ពេលសម្រាប់អ្នក និងទារករបស់អ្នក ដោយហេតុថាអង្គបដិបក្ខនឹងចម្លងទៅឲ្យទារករបស់អ្នកនៅក្នុងស្បូន។ ការចាក់ថ្នាំបង្ការរោគក្អកមាន់ក្នុងអំឡុងពេលមានផ្ទៃពោះ គឺមានសុវត្ថិភាពទាំងម្តាយ និងទាំងទារករបស់គេដែលមិនទាន់កើតមក។

អ្នកគួរស្នើសុំឲ្យដៃគូរបស់អ្នក ជីដូនជីតាទារករបស់អ្នក និងអ្នកមើលថែពេញវ័យជិតស្និទ្ធណាម្នាក់ឲ្យគេបានចាក់ថ្នាំបង្ការរោគផងដែរ ឲ្យបានយ៉ាងហោចណាស់ពីរអាទិត្យមុនពេលទារករបស់អ្នកកើតមក ប្រសិនបើគេពុំបានចាក់ថ្នាំបង្ការរោគក្អកមាន់ក្នុងរយៈពេល១០ឆ្នាំកន្លងទៅ។

## គ្រុនផ្តាសាយធំ

ជម្ងឺគ្រុនផ្តាសាយធំក្នុងពេលមានផ្ទៃពោះ អាចមានសភាពធ្ងន់ធ្ងរដោយកើនឡើងនូវគ្រោះថ្នាក់នៃការសម្រាលកូនមិនគ្រប់ខែ ហើយទារកកើតមកមិនគ្រប់ទម្ងន់។ ការចាក់ថ្នាំបង្ការគ្រុនផ្តាសាយធំក្នុងអំឡុងពេលមានផ្ទៃពោះ មានសុវត្ថិភាព និងមានប្រសិទ្ធិភាព ហើយត្រូវបានណែនាំយ៉ាងខ្លាំងចំពោះស្ត្រីមានផ្ទៃពោះគ្រប់រូប។ ថ្នាំបង្ការគ្រុនផ្តាសាយធំ ផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់ស្ត្រីមានផ្ទៃពោះ ហើយក៏ផ្តល់ការការពារផងដែរសម្រាប់ទារករបស់អ្នកក្នុងស្បូន និងរហូតដល់៦ខែបន្ទាប់ពីកំណើតទារក។

# បន្ទាប់ពីកំណើតទារករបស់អ្នក

វាមានសុវត្ថិភាពសម្រាប់អ្នក ដើម្បីទទួលការចាក់ថ្នាំបង្ការរោគតាមការណែនាំឲ្យបានភ្លាមៗបន្ទាប់ពីទារកកើតមក ទោះបីជាអ្នកកំពុងបំបៅកូនដោយទឹកដោះម្តាយក៏ដោយ។ អ្នកគួរទទួលការចាក់ថ្នាំបង្ការរោគក្អកមាន់មុននឹងអ្នកចាកចេញពីមន្ទីរពេទ្យ ប្រសិនបើអ្នកពុំបានចាក់ថ្នាំបង្ការរោគក្នុងអំឡុងពេលបីខែចុងក្រោយនៃការមានផ្ទៃពោះទេ។

ការចាក់ថ្នាំបង្ការរោគលើកទីមួយសម្រាប់ទារករបស់អ្នក គឺរោគរលាកថ្លើមប្រភេទ B ត្រូវបានណែនាំបន្ទាប់ពីសម្រាលកូនរួច ហើយការចាក់ថ្នាំបង្ការរោគលើកក្រោយតាមគំរោង នឹងដល់ពេលកំណត់នៅពេលទារករបស់អ្នកមានអាយុ៦-៨អាទិត្យ។

ទារកកើតពីម្តាយដែលមានរោគរលាកថ្លើមប្រភេទ B ត្រូវការធ្វើតេស្តឈាម៣ខែក្រោយពេលបានបំពេញវគ្គចាក់ថ្នាំបង្ការរោគរលាកថ្លើមប្រភេទ B ដើម្បីឲ្យប្រាកដច្បាស់ថាគេបានទទួលការការពារ។ អ្នក និងវេជ្ជបណ្ឌិតរបស់អ្នកអាចទទួលសំបុត្ររំលឹកមកពីក្រសួងសុខាភិបាលរដ្ឋញូវសៅវែល។

*ជាការសំខាន់ដែលអ្នកត្រូវចាក់ថ្នាំបង្ការរោគរបស់អ្នកឲ្យបានទាន់បច្ចុប្បន្នភាព ដោយហេតុថាភាពស៊ាំនឹងជម្ងឺរបស់អ្នក នឹងត្រូវចម្លងទៅឲ្យទារករបស់អ្នក។*